+

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សហព័ន្ធកីឡាបាល់បោះកម្ពុជា**
Cambodia Basketball Federation
លេខ៖ ..........០៩៣............ស.ប.ក

## សេចក្តីជូនដំណឹង

**កម្មវត្ថុ៖** អញ្ជើញកីឡាករ កីឡាការនី ០២រូប ក្នុងមួយក្រុម ជាតំណាងក្រុមនីមួយៗ ដែលបានជាប់ឈ្មោះក្នុងការប្រកួត “**ពានរង្វាន់បាល់បោះ** *TNAOT ៣x៣*” ចូលរួមប្រជុំក្នុងសន្និសីទកាសែត ប្រកាសអំពីការប្រកួត និងការចាប់ពូលនៃវិញ្ញាសាទាំងបួនប្រភេទ ។

តបតាមកម្មវត្ថុខាងលើ សហព័ន្ធកីឡាបាល់បោះកម្ពុជា មានកិត្តិយសសូមជម្រាបជូន កីឡាករ កីឡាករនី ដែលបានជាប់ឈ្មោះក្នុងការប្រកួតមេត្តាជ្រាបថា ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ វិស័យកីឡាបាល់បោះនៅកម្ពុជា សហព័ន្ធកីឡាបាល់បោះកម្ពុជាបានសហការជាមួយសារព័ត៌មាន TNAOT APP ដោយទទួលបានសិទ្ធិពេញលេញ និងការគាំទ្រយ៉ាងពេញទំហឹងពីអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំយុវជននិងកីឡាក្នុងការរៀបចំកម្មវិធី សន្និសីទកាសែត ប្រកាសអំពីកម្មវិធីប្រកួតពានរង្វាន់បាល់បោះ TNAOT ៣X៣ និង ការចាប់.ពូលប្រកួតនៃវិញ្ញាសាទាំង៤រួម ៖ (១). វិញ្ញាសាកម្រិតមធ្យមសិក្សាបុរស (២). វិញ្ញាសាកម្រិតឧត្តមសិក្សាបុរស (៣). វិញ្ញាសាមហាជនបុរស និង (៤). វិញ្ញាសាមហាជននារី ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២២ នៅសណ្ឋាគារ Oakwood Premier Phnom Penh។

អាស្រ័យដូចបានជម្រាបជូនខាងលើសហព័ន្ធកីឡាបាល់បោះកម្ពុជាសូមធ្វើការអញ្ជើញ កីឡាករ កីឡាការនី តំណាងក្រុមនីមួយៗចំនួន០២រូប ដែលបានជាប់ឈ្មោះក្នុងការប្រកួត “**ពានរង្វាន់បាល់បោះ** *TNAOT ៣x៣*” ចូលរួមសន្និសីទកាសែត ស្តីអំពីការបើកកម្មវិធី “**ពានរង្វាន់បាល់បោះ** *TNAOT ៣x៣*” និងការចាប់ពូលវិញ្ញាសាទាំង៤ប្រភេទ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមកីឡាករ កីឡាការនីនៃតំណាងក្រុម នីមួយៗបញ្ជាក់អំពីការចូលរួមកម្មវិធីនេះមកកាន់ក្រុមការងារ និងសូមបញ្ជូនឈ្មោះតំណាងនៃក្រុមនីមួយៗតាមរយៈ Google Form ដែលក្រុមការងារបានរៀបចំ សម្រាប់ទំនាក់ទំនងព័ត៌មានលំអិតសូមទាក់ទងតាមលេខទូរសព្ទ៖ **០៧៧ ២៧៥ ១០៥**។

សូមកីឡាករ កីឡាការនីទាំងអស់មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

- ព័ត៌មានបន្ថែម សូមពិនិត្យនូវរបៀបវារៈនៃកម្មវិធី ដែលបានចម្លងជូនភ្ជាប់ជាមួយចំនួន ០១ច្បាប់ដូចខាងក្រោមនេះ។

ថ្ងៃច័ន្ទ ៧រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៧ខែ តុលា ឆ្នាំ ២០២២

**សហព័ន្ធកីឡាបាល់បោះកម្ពុជា**
**ជ.អគ្គលេខាធិការ**
**អគ្គលេខាធិការរង**

**ជួន ទ្រីម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ   សាសនា   ព្រះមហាក្សត្រ**

*Oakwood Premier Phnom Penh*

**របៀបវារៈ**
**កម្មវិធីសន្និសីទ កាសែត និងការចាប់ពូល វិញ្ញាសាទាំង ៤ប្រភេទ**
**ក្នុងកម្មវិធី "ពានរង្វាន់បាល់បោះ TNAOT ៣x៣"**
**នៅថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦**
**ត្រូវនឹងថ្ងៃទី២១ ខែ តុលា ឆ្នាំ២០២២**
**នៅសណ្ឋាគារ** *Oakwood Premier Phnom Penh*

| | |
|---|---|
| ៧:៣០-៨:០០ | គណៈអធិបតី និងសមាជិកសមាជិកា អញ្ជើញដល់ និងចុះឈ្មោះ |
| | ចាក់វិដេអូ រូបភាព និង ចម្រៀងកំដរកម្មវិធី |
| | អាហារសម្រន់ |
| ៨:០០-៨:១០ | ចាប់ផ្តើមកម្មវិធី |
| | ឧទ្ទេសនាមគណៈអធិបតី |
| ៨:១០-៨:២០ | សង្ខេបអំពីវត្ថុបំណងកម្មវិធី និង មតិស្វាគមន៍ភ្ញៀវកិត្តិយស |
| | ដោយ **លោក តាំង ពីងជាំង** ( Tony ) **អគ្គនាយកនៃសារព័ត៌មាន** TNAOT APP |
| ៨:២០-៨:៤០ | សារបាននៃការរៀបចំកម្មវិធី ការជ្រើសរើសតំណាងក្រុមនៃវិញ្ញាសានីមួយៗ |
| | ច្បាប់នៃការប្រកួតនៃវិញ្ញាសានីមួយៗ ដោយ **លោក** Austin Koledoy |
| | **អគ្គលេខាធិការនៃ សព័ន្ធបាល់បោះកម្ពុជា** |
| ៨:៤០-៨:៥៥ | ការថ្លៃចំណាប់អារម្មណ៍នៃកម្មវិធី នឹង ផ្តល់អនុសាសន៍ទៅកាន់ កីឡាករ កីឡាការនីដោយ |
| | **ឯកឧត្តម ផុស សុវណ្ណ  អគ្គនាយក នៃអគ្គនាយកដ្ឋាន** |
| | **ព័ត៌មាន និង សោតទស្សន៍** |
| ៨:៥៥-៩:១០ | ការថ្លែងចំណាប់អារម្មណ៍នៃកម្មវិធី នឹងផ្តល់អនុសាសន៍ទៅកាន់កីឡាករ កីឡាការនីដោយ |
| | **ឯកឧត្តម** Wang Wentian **ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា** |
| ៩:១០-៩:២៥ | ការថ្លែងចំណាប់អារម្មណ៍ **ឯកឧត្តម អ៊ុក សិទ្ធិជាតិ អគ្គនាយកនៃ** |
| | **អគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា** |
| ៩:២៥-៩:៤០ | ពិធីការ អញ្ជើញគណៈអធិបតី ឡើងចាប់បាល់ទាំង ៤ ប្រភេទវិញ្ញាសា |
| | ១.កម្រិតមធ្យមសិក្សាដោយ **ឯកឧត្តម** Wang Wentian |
| | ២.កម្រិត ឧត្តមសិក្សាដោយ **ឯកឧត្តម ផុស សុវណ្ណ** |
| | ៣.កម្រិតមហាជនដោយ **ឯកឧត្តម អ៊ុក សិទ្ធិជាតិ** |
| | ៤.កម្រិតមហាជននារីដោយ **លោក** Austin Koledoy |
| ៩:៤០-៩:៥៥ | ការបើកបាល់និងប្រកាសនៃពូលនីមួយៗដោយតំណាង **មន្ត្រីអាជ្ញាកណ្តាល** |
| ៩:៥៥-១០:២០ | ប្រកាសបិទកម្មវិធី និងថតរូបអនុស្សាវរីយ៍ |
| | ចែកឯកសណ្ឋាននិងប័ណ្ណសម្គាល់ខ្លួនកីឡាករប្រកួតជូនដំណាងកីឡាករនៃក្រុមនីមួយៗ |

សូមរក្សាសិទ្ធិធ្វើការកែប្រែក្នុងករណីចាំបាច់!